សលាកប័ត្រព័ត៌មាន ៖ ពិធីសារបន្ថែមលើ អនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ (ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ)

ស្ថានភាពបច្ចុប្បន្ននៃច្បាប់ ៖ ចូលជាធរមាននៅកម្ពុជាកាលពីថ្ងៃទី១២ ខែមករា ឆ្នាំ២០១១

សង្ខេប ៖ តាមរយៈការផ្តល់សច្ចាប័នលើ ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) បានត្រួសត្រាយផ្លូវដើម្បីឲ្យស្ត្រីជាបុគ្គល និងជាក្រុម ដែលជឿជាក់ថាសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន អាចដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការរបស់អង្គការ សហប្រជាជាតិ ធ្វើការលើសិទ្ធិស្ត្រី ហើយព្រមទាំងអាចផ្តល់មធ្យោបាយបន្ថែមទៀតសម្រាប់ស្ត្រីដើម្បីស្វែងរកនូវដំណោះស្រាយចំពោះការរំលោភសិទ្ធិពួកគេ ។

សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ បង្ហាញទិដ្ឋភាពរួមរបស់ ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ ដែលកម្ពុជាបានចុះសច្ចាប័នកាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ ដែលចូលជាធរមាននៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១១ ។ ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ ដែលចូលជាធរមានមួយនេះ បានអនុញ្ញាតឲ្យស្ត្រីជាបុគ្គល និងជាក្រុម ដែលជឿជាក់ថាសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន ក្នុងការដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការរបស់អង្គការសហប្រជាជាតិ ដែលធ្វើការលើការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ ជាស្តាប័នអ្នកជំនាញឯករាជ្យដែលតាមដានលើការអនុវត្តន៍ អនុសញ្ញា ស៊ី ដ (គណៈកម្មាធិការ) ។ សលាកប័ត្រព័ត៌មាននេះសរសេរឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) ។

តើពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ ជាអ្វី?

អនុសញ្ញា ស៊ី ដ ត្រូវបានចាត់ទុកថាជា "ច្បាប់អន្តរជាតិស្តីពីសិទ្ធិ" សម្រាប់ស្ត្រី ។ អនុសញ្ញានេះ គឺជាឯកសារយ៉ាងក្បោះក្បាយទាក់ទងនឹងការរំលោភបំពានសិទ្ធិមនុស្ស ដែលកើតមានលើមូលដ្ឋានការរើសអើងលើយេនឌ័រ ។ អនុសញ្ញានេះបញ្ជាក់បន្ថែមជាវិជ្ជមានមកលើគោលការណ៍សមភាព ដែលតម្រូវឲ្យរដ្ឋជាភាគីចាត់ "វិធានការសមរម្យទាំងឡាយ ដើម្បីធានាការអភិវឌ្ឍន៍ និងវឌ្ឍនភាពរបស់ស្ត្រី ក្នុងគោលបំណងធានាឲ្យពួកគេអាចប្រើ និងទទួលផលប្រយោជន៍ពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅលើមូលដ្ឋានសមភាពជាមួយបុរស" ។

ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ គឺជាមធ្យោបាយដើម្បីដាក់ឲ្យរដ្ឋទទួលខុសត្រូវចំពោះការប្តេជ្ញាចិត្តរបស់ខ្លួន ដើម្បីធានាថានឹងមានការបានទទួលផលប្រយោជន៍ពីសិទ្ធិដែលមានកំណត់ក្នុង អនុសញ្ញា ស៊ី ដ។ ពិធីសារនេះ គឺជាសន្ធិសញ្ញានៃសិទ្ធិរបស់ខ្លួន ដូច្នេះ រដ្ឋដែលជាភាគីរបស់ អនុសញ្ញា ស៊ី ដ ត្រូវតែចុះហត្ថលេខា ទទួលស្គាល់ ឬចុះសច្ចាប័ន លើពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ ដើម្បីឲ្យមានការពិចារណាលើញត្តិ ឬពាក្យបណ្តឹងពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិស្ត្រីភេទ ។ ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ មាននីតិវិធីពីរសំខាន់ៗ ដែលអាចឲ្យការរំលោភសិទ្ធិស្ត្រីត្រូវបានយកមកពិចារណាក្នុងថ្នាក់អន្តរជាតិ ៖

(១) នីតិវិធីប្រាស្រ័យទាក់ទង ៖ នីតិវិធីនេះផ្តល់មធ្យោបាយឲ្យបុគ្គល ឬក្រុម ដើម្បីដាក់ញត្តិ ឬពាក្យបណ្តឹងដោយផ្ទាល់ទៅកាន់គណៈកម្មាធិការ (មាត្រា២ នៃ ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ) ។

(២) នីតិវិធីស៊ើបអង្កេត ៖ នីតិវិធីនេះអនុញ្ញាតឲ្យគណៈកម្មាធិការ ធ្វើការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ឬជាប្រព័ន្ធ ក្នុងប្រទេសដែលជាភាគីរបស់ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ (មាត្រា៨ នៃពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ) ។

នីតិវិធីប្រាស្រ័យទាក់ទង

ដើម្បីអាចឲ្យបុគ្គល ឬក្រុមនៅក្នុងប្រទេសកម្ពុជាអាច មានលទ្ធភាពចំពោះនីតិវិធីប្រាស្រ័យទាក់ទង ពាក្យបណ្តឹងគួរតែធ្វើឡើងជាលាយលក្ខណ៍អក្សរទៅកាន់គណៈកម្មាធិការ ។ ស្របទៅតាមមាត្រា៣ នៃពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ ពាក្យបណ្តឹងមិនអាចធ្វើឡើងជាអានាមិកបានទេ ដូច្នេះ បណ្តឹងនោះត្រូវតែមានឈ្មោះរបស់ដើមបណ្តឹង ។ មុនពេលដែលគណៈកម្មាធិការអាចពិចារណានូវភាពស្របច្បាប់នៃពាក្យបណ្តឹង គណៈកម្មាធិការនោះត្រូវតែកំណត់ឲ្យច្បាស់សិនថា ពាក្យបណ្តឹងបានប្រើប្រាស់អស់នូវដំណោះស្រាយទាំងប៉ុន្មានដែលមានក្នុងស្រុក លើកលែងតែការដាក់ពាក្យសុំស្នើដំណោះស្រាយទាំងនេះត្រូវបានអូសបន្លាយរយៈពេលយូរហួសហេតុ ឬមិនទំនងជានាំមកនូវភាពធូរស្បើយដ៏មានប្រសិទ្ធិភាព (សូមអាន មាត្រា៥ នៃពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ) ។ គោលការណ៍គតិយុត្តរបស់គណៈកម្មាធិការ និងគណៈកម្មាធិការសិទ្ធិមនុស្សដទៃទៀតរបស់អង្គការសហប្រជាជាតិ រួមជាមួយនឹងយន្តការដាក់ពាក្យបណ្តឹង បានបង្ហាញថាដើម្បីឲ្យបានស្វែងរកនូវដំណោះស្រាយទាំងប៉ុន្មានដែលមាននៅក្នុងស្រុកអស់លទ្ធភាពហើយ ជនរងគ្រោះត្រូវតែស្វែងរកឲ្យអស់ពីលទ្ធភាពនូវដំណោះស្រាយផ្នែកយុត្តាធិការ ដូចជា ការពិនិត្យរបស់សាលាដំបូង និងតុលាការកំពូល និងរួមទាំងដំណោះស្រាយផ្នែករដ្ឋបាល ដែលមាន ការដាក់ពាក្យបណ្តឹងទៅ គណៈកម្មការសិទ្ធិ

មនុស្ស ក្នុងករណីដែលមាន គឺត្រូវមានយ៉ាងគ្រប់គ្រាន់ និងមានប្រសិទ្ធភាព ។ ក្នុងករណី ប្រទេសសាកាលដូ ជាមួយនឹង ចក្រភពអង់គ្លេស គណៈកម្មាធិការបានរកឃើញថា នៅមិនទាន់មានការស្វែងរកដំណោះស្រាយនៅក្នុងស្រុកឲ្យអស់ពីលទ្ធភាពនៅឡើយ ព្រោះថាជនរងគ្រោះបានត្រឹមតែស្វែងរកដំណោះស្រាយផ្នែកនីតិវិធីផ្នែករដ្ឋបាល មិនទាន់បានរកដំណោះស្រាយផ្នែកយុត្តាធិការ ។ ការដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការ ក៏នឹងត្រូវពិចារណាថាមិនអាចធ្វើទៅបានក្នុងករណីដែល (១) បញ្ហាដដែលនេះត្រូវបានគណៈកម្មាធិការពិនិត្យរួចហើយ (២) ផ្ទុយនឹងបទប្បញ្ញត្តិរបស់អនុសញ្ញា ស៊ី ដ (៣) មិនបានបញ្ហាក់មូលហេតុច្បាស់លាស់ ឬគ្មានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើជាអំណះអំណាង (៤) ជាការរំលោភសិទ្ធិដាក់ពាក្យបណ្តឹង ឬ (៥) អង្គហេតុដែលជាកម្មវត្ថុនៃបណ្តឹងបានកើតមាន នៅមុនថ្ងៃចូលជាធរមាននៃពិធីសារនេះសម្រាប់ រដ្ឋភាគីពាក់ព័ន្ធ បើពុំនោះទេលុះត្រាតែអង្គហេតុនោះបានបន្តរហូតដល់ក្រោយកាលបរិច្ឆេទនៃពិធីសារនោះ ។ នៅគ្រប់ពេល បន្ទាប់ពីការទទួលពាក្យបណ្តឹង និងនៅមុនពេលឈានដល់ការសម្រេចលើអង្គសេចក្តី គណៈកម្មាធិការអាចបញ្ជូនទៅរដ្ឋភាគីពាក់ព័ន្ធ ដើម្បីពិនិត្យជាបន្ទាន់លើសំណើដែលរដ្ឋភាគីចាត់នីតិវិធីបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីជៀសវាងការអាចកើតមាននូវការគេចវេះ "មិនជួសជុលសំណងការខូចខាតដល់ជនរងគ្រោះម្នាក់ ឬច្រើននាក់ ដែលអះអាងថាបានទទួលរងការរំលោភ" ។ (មាត្រា ៥(១) នៃពិធីសារបន្ថែមលើអនុសសញ្ញា ស៊ី ដ) ។

លើកលែងតែគណៈកម្មាធិការពិចារណាឃើញថា ពាក្យបណ្តឹងនោះមិនអាចទទួលយកបាន ដែលមិនពាក់ព័ន្ធនឹងរដ្ឋភាគីពាក់ព័ន្ធ និងដោយតែមានការយល់ព្រមពីអ្នកដែលមានអំណាចសម្រេចចិត្ត ពាក្យបណ្តឹងដែលពួកគេបានកំណត់អាចឲ្យរដ្ឋភាគីដឹង គណៈកម្មាធិការនឹងនាំយកពាក្យបណ្តឹងនេះដើម្បីឲ្យភាគីរដ្ឋផ្តោតការចាប់អារម្មណ៍ ។ គណៈកម្មាធិការនឹងពិចារណានូវព័ត៌មានដែលពួកគេអាចស្វែងរកបាន ឬក៏តំណាងដោយ បុគ្គល ឬក្រុម និងភាគីរដ្ឋ នឹងរៀបចំកិច្ចប្រជុំដើម្បីពិនិត្យមើលនូវពាក្យបណ្តឹងទាំងនោះ ។ បន្ទាប់មក គណៈកម្មាធិការនេះនឹងបញ្ជូនការយល់ឃើញរបស់ខ្លួន រួមជាមួយអនុសាសន៍ ប្រសិនបើមាន ទៅកាន់ភាគីពាក់ព័ន្ធ ។ អនុសាសន៍ទាំងនេះ អាចរួមមាន ដំណោះស្រាយសម្រាប់ជនរងគ្រោះ និងនីតិវិធីដើម្បីបញ្ឈប់ការរំលោភសិទ្ធិមនុស្សជាបន្តបន្ទាប់ ។ ភាគីរដ្ឋមានរយៈពេល ៦ខែ ដើម្បីផ្តល់ការឆ្លើយតបជាលាយលក្ខណ៍អក្សររួមទាំងព័ត៌មានទាក់ទងនឹងនីតិវិធីដែលបានដាក់ចេញ ស្របទៅនឹងការយល់ឃើញ និងអនុសាសន៍ពីគណៈកម្មាធិការ ។ ការសម្រេចរបស់គណៈកម្មាធិការ មិនមែនជាការជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ទេ ប៉ុន្តែ គណៈកម្មាធិការអាចប្រើប្រាស់នីតិវិធី និងឥទ្ធិពលរបស់ខ្លួនដើម្បីបញ្ចុះបញ្ចូលឲ្យរដ្ឋអនុវត្តតាមអនុសាសន៍ទាំងនោះ ។

នីតិវិធីស៊ើបអង្កេត

នីតិវិធីស៊ើបអង្កេត អនុញ្ញាតឲ្យគណៈកម្មាធិការរៀបចំធ្វើការពិនិត្យពិច័យមកលើរដ្ឋភាគី ដែលគណៈកម្មាធិការនោះបានទទួលព័ត៌មានដែលទុកចិត្តបាន ក្នុងការបញ្ហាក់ពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ឬជាប្រព័ន្ធ ដែលបានកំណត់រួចជាស្រេចក្នុង អនុ-សញ្ញា ស៊ី ដ ។ អាស្រ័យលើព័ត៌មានដែលពួកគេទទួលបាន គណៈកម្មាធិការអាចនឹងស្នើឲ្យសមាជិកម្នាក់ ឬពីរនាក់នៅក្នុងគណៈ-កម្មាធិការរៀបចំស៊ើបអង្កេត និងរាយការណ៍ត្រលប់មកគណៈកម្មាធិការវិញ ។ ប្រសិនបើចាំបាច់ និងដោយមានការយល់ព្រមពីរដ្ឋភាគី ការស៊ើបអង្កេតនេះអាចរួមមានទាំងការធ្វើទស្សនកិច្ចទៅកាន់ទឹកដីនៃរដ្ឋនោះ (មាត្រា ៨(២) នៃពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ) ។ គណៈកម្មាធិការនោះ ត្រូវបញ្ជូនសេចក្តីសន្និដ្ឋានទាំងនេះទៅរដ្ឋភាគីពាក់ព័ន្ធ រួមជាមួយនឹងការផ្តល់យោបល់ ឬអនុសាសន៍ ។ ភាគីរដ្ឋដែលពាក់ព័ន្ធមានរយៈពេល ៦ខែ ក្នុងការបញ្ជូនសេចក្តីអង្កេត របស់ខ្លួនមកកាន់គណៈកម្មាធិការវិញ ។ ប្រសិនបើចាំបាច់ បន្ទាប់ពីរយៈពេល ៦ខែ គណៈកម្មាធិការអាចស្នើឲ្យភាគីរដ្ឋដើម្បីផ្តល់ព័ត៌មានស្តីពីនីតិវិធីដែលរដ្ឋបានដាក់ចេញដើម្បីឆ្លើយតបទៅនឹងការស៊ើបអង្កេត ។

សេចក្តីសន្និដ្ឋាន

ការចុះសច្ចាប័នរបស់រដ្ឋាភិបាលមកលើ ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ បង្ហាញនូវមធ្យោបាយបន្ថែមមួយទៀត ដែលស្ត្រី និងក្មេងស្រីជាបុគ្គល ឬក៏ជាក្រុម អាចស្វែងរកឲ្យមានដំណោះស្រាយចំពោះការរំលោភសិទ្ធិរបស់ពួកគេ ។ ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ ទើបតែចូលជាធរមាន រយៈពេលមួយឆ្នាំប៉ុណ្ណោះទេ ហើយមកទល់បច្ចុប្បន្ន គឺគ្មានញត្តិ ឬបណ្តឹងណាដែលពាក់-ព័ន្ធនឹងការរំលោភលើអនុសញ្ញា ស៊ី ដ ដែលអាចកើតមាន ត្រូវបានប្រកាសជាសាធារណៈនៅឡើយ ។ អ្វីដែលសំខាន់គឺស្ត្រីកម្ពុជាត្រូវដឹងពីមធ្យោបាយដែលពួកគេអាចធ្វើបាន ក្នុងករណីដែលពួកគេចង់ស្វែងរកឲ្យមានដំណោះស្រាយចំពោះការរំលោភសិទ្ធិមនុស្សរបស់ពួកគេ ។ ជាចុងបញ្ចប់នេះ ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ ជាពិសេសតាមរយៈនីតិវិធីប្រាស្រ័យទាក់ទង មិនត្រឹមតែបង្ហាញនូវមធ្យោបាយក្នុងការធានាឲ្យមានដំណោះស្រាយចំពោះការរំលោភលើសិទ្ធិស្ត្រី និងក្មេងស្រីប៉ុណ្ណោះទេ ប៉ុន្តែ គឺជាមធ្យោ-បាយដើម្បីឲ្យរដ្ឋាភិបាលទទួលខុសត្រូវចំពោះកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ។ ម.ស.ម.ក យល់ឃើញថាការផ្តល់សច្ចាប័នរបស់រដ្ឋាភិបាលចំពោះ ពិធីសារបន្ថែមលើអនុសញ្ញា ស៊ី ដ គឺជាជំហានដ៏រីកចម្រើនមួយក្នុងការទទួលស្គាល់សិទ្ធិស្ត្រីនៅកម្ពុជា ។ យើងសង្ឃឹមថាចំណុចនេះបង្ហាញឲ្យឃើញពី ឆន្ទៈរបស់រដ្ឋាភិបាលក្នុងការបន្តការងារដើម្បីឆ្ពោះទៅរកការធានាឲ្យមានការការពារ និងការលើកតម្កើងសិទ្ធិស្ត្រីនៅកម្ពុជា ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង លោក អ៊ូ វីរៈ (+៨៥៥ (0) ១២ ៤០ ៤០ ៥១ ឬអ៊ីម៉ែល៖ ouvirak@cchrcambodia.org **ឬ អ្នកស្រី ជរ ច័ន្ទធីតា (+៨៥(0) ១២ ៥១ ៥៥ ០៦ ឬអ៊ីម៉ែល ៖** thyda@cchrcambodia.org ។

Cambodian Center for Human Rights